# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៧ ស.ស.រ

## សេចក្តីសំរេច

### ស្តីពី

### ការបង្កើតក្រុមការងារអន្តរក្រសួងសំរាប់សួរពត៌មានបន្ថែម ពីជនល្មើសឈ្មោះ ចំន្ទ យីពុន នៅខេត្តពោធិសាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់ចំពោះមុខ

## សំរេច

**ប្រការ ១.-** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងសំរាប់សួរពត៌មានបន្ថែមពីជនល្មើសឈ្មោះ ច័ន្ទ យីពុន នៅខេត្តពោធិសាត់ ដែលមានសមាសភាព :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម ឈន អៀម | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ប្រធាន |
| ២. | លោក ខឹម វិសិដ្ឋ | ប្រធាននាយកដ្ឋានអប់រំ វប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣. | លោកឧត្តមសេនីយ៍ត្រី ង៉ែ ស៊ីណារិទ្ធ | ប្រធាននាយកដ្ឋានពត៌មានទូទៅ អគ្គស្នងការដ្ឋាន នគរបាលជាតិ | សមាជិក |
| ៤. | លោក ឌី សុកជាន | អនុប្រធានទី១នាយកដ្ឋានកិច្ចការនយោបាយ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៥. | លោកឧត្តមសេនីយ៍ មាស រ៉េន | នាយករងនាយកដ្ឋានស្រាវជ្រាវចារកិច្ច នៃក្រសួងការពារជាតិ | សមាជិក |

**ប្រការ ២.-** ក្រុមការងារអន្តរក្រសួងនេះ មានភារកិច្ច ៖

- ចុះទៅសិក្សាស្វែងយល់ និងសួរពត៌មានបន្ថែមពីជនល្មើសឈ្មោះ ច័ន្ទ យីពុន ដែលបានឃាត់ខ្លួនកាលពី ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣ នៅខេត្តពោធិសាត់ ជុំវិញការប្រកាសខ្លួនជាតួអង្គព្រះពោធិសត្វ ព្រះបាទធម្មិករាជា ដើម្បីជាមូលដ្ឋានក្នុងការស្រាវជ្រាវរកខ្សែបណ្តាញរបស់បក្ខពួកធម្មិករាជានៅតាមបណ្តាខេត្ត-ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- បូកសរុបវាយតំលៃ និងលើកវិធានការដើម្បីធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេចតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣.-**
- សមាជិកក្រុមការងារអន្តរក្រសួងនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។
- ក្រុមការងារអន្តរក្រសួងនេះត្រូវរំសាយនៅពេលចប់ភារកិច្ច ។

**ប្រការ ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តពោធិសាត់ អភិបាលខេត្ត-ក្រុង និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ២០០៤

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- កាលប្បវត្តិ-ឯកសារ